ក្រសួងឧស្សាហកម្មនិងសិប្បកម្ម

# កិច្ចប្រជុំផ្ទៃក្នុងក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ របស់រាជរដ្ឋាភិបាលកម្ពុជា នៅខេត្តកំពត



នាព្រឹកថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ២០១៦ នៅរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ មានបើកកិច្ចប្រជុំផ្ទៃក្នុងក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ របស់រាជរដ្ឋាភិបាលកម្ពុជា នៅខេត្តកំពត ដើម្បីពិនិត្យ និងស្វែងរកដំណោះស្រាយជូនប្រជាពលរដ្ឋដែលទទួលបានតាមរយៈអង្គវេទិកាសាធារណៈកន្លងមក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងជាប្រធានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ខេត្តកំពត** ព្រមទាំងមានវត្តមាន ឯកឧត្តមអនុប្រធានក្រុមការងារថ្នាក់ជាតិ ឯកឧត្តម លោកជំទាវ សមាជិកក្រុមការងារថ្នាក់ជាតិទទួលបន្ទុកជាប្រធានក្រុមការងារតាមក្រុង ស្រុក នីមួយៗ អភិបាលក្រុង ស្រុក ទាំង៨ និងមន្ត្រីពាក់ព័ន្ធមួយចំនួនទៀត។



កិច្ចប្រជុំបានផ្តោតសំខាន់ទៅលើការពិនិត្យបញ្ហាប្រឈម និងសំណូមពរនានារបស់ប្រជាពលរដ្ឋដែលទទួលបានតាមរយៈអង្គវេទិកាសាធារណៈកន្លងមក សំដៅស្វែងរកដំណោះស្រាយឆ្លើយតបជូនប្រជាពលរដ្ឋវិញ។ នៅក្នុងនោះមានបញ្ហាធំៗចំនួន ៨៤ ដែលអង្គប្រជុំលើកយកមកពិនិត្យទៅតាមករណីនីមួយៗ ហើយដាក់ចេញជាវិធានការដោះស្រាយទៅតាមស្ថានភាពជាក់ស្តែងនៃបញ្ហាទាំងនោះ។ ជាលទ្ធផលអង្គប្រជុំបានសម្រេចប្រគល់ភារកិច្ចឲ្យអាជ្ញាធរថ្នាក់ស្រុក ខេត្ត បន្តដោះស្រាយសំណូមពរណាដែលស្ថិតនៅក្នុងលទ្ធភាពឆ្លើយតបក្នុងក្របខណ្ឌសមត្ថកិច្ច ស្រុក ខេត្ត និងបញ្ហាមួយចំនួនទៀត ក្រសួងឧស្សាហកម្ម និងសិប្បកម្ម នឹងទទួលយកទៅពិចារណាដោះស្រាយដោយផ្ទាល់ ហើយមួយចំនួនដែលនៅ

សល់ ក្នុងនាមប្រធានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ខេត្តកំពត **ឯកឧត្តមទេសរដ្ឋមន្ត្រី** នឹងធ្វើលិខិតអន្តរាគមន៍ទៅក្រសួងស្ថាប័នដែលពាក់ព័ន្ធ ដើម្បីសុំការគូសបញ្ជាក់អំពីលទ្ធភាពក្នុងការដោះស្រាយជូនប្រជាពលរដ្ឋដូចជា បញ្ហាពាក់ព័ន្ធនឹងវិស័យអប់រំ សុខាភិបាល ធនធានទឹក កសិកម្ម រ៉ែ និងថាមពល ។ល។

( Credit : H.E. OST )




រៀបរៀង និងសម្រួលដោយៈ

នាយកដ្ឋានផែនការ ស្ថិតិ សហប្រតិបត្តិការ និងការងារអាស៊ាន